សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣

# យុត្តិធម៌សម្រាប់អ្នកសារព័ត៌មាន

ការជួបជុំដើម្បីបញ្ចប់និទណ្ឌភាពលើជនល្មើសលើករណីរសម្លាប់អ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា




យើងខ្ញុំជាអង្គការដៃគូរមួយចំនួន នឹងរៀបចំពិធីជួបជុំមួយនៅពហុកីឡាដ្ឋានជាតិ អូឡាំពិកនៅថ្ងៃទី២១ ខែវិច្ឆិកានេះ នៅវេលាម៉ោង ៥:៣០ នាទីល្ងាច ដើម្បីទាមទារយុត្តិធម៌ដល់ អ្នកសារព័ត៌មាន ចំនួន១១រូប ដែលត្រូវបានគេសម្លាប់កាលពី២០ឆ្នាំមុន។

## គោលបំណងនៃកម្មវិធី

ការអញ្ជើញមកដល់ និងការចែកកន្សែងសម្រាប់ចងលើក្បាល បដា ផ្កា រួមនឹងទៀន

ពិធីសូត្រមន្តរបស់ព្រះសង្ឃ

ការថ្លែងសុន្ទរកថារបស់ភរិយា លោក ហង្ស សេរីឧត្តម

នៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ សហគមន៍អន្តរជាតិនឹងរៀបចំទិវាអន្តរជាតិលើកទី៣ ដើម្បីបញ្ចប់និទណ្ឌភាព។ និទណ្ឌភាពនៅប្រទេសកម្ពុជា នៅតែជាបញ្ហាដ៏ធំមួយ ក្នុងការពង្រឹងនីតិរដ្ឋ និង ធ្វើឲ្យប្រជាពលរដ្ឋក្នុងប្រទេសនេះទទួលបាននូវយុត្តិធម៌។ យើងខ្ញុំសូមអញ្ជើញអ្នកសារព័ត៌មាន ក៏ដូចជា ប្រព័ន្ធផ្សព្វផ្សាយ និងជនរងគ្រោះដែលពុំទាន់ទទួលបាននូវយុត្តិធម៌ ដោយសារតែនិទណ្ឌភាព ចូលរួមទាំងអស់គ្នាក្នុងសាមគ្គីភាព ដើម្បីប្រារព្ធពិធីនៅកន្លែងដែលអ្នកសារព័ត៌មាន លោក ឃឹម សំបូរ ត្រូវបានគេសម្លាប់ កាលពីឆ្នាំពី២០០៨ និងសុំឲ្យរដ្ឋាភិបាលជួយផ្តល់យុត្តិធម៌ជូនជនរងគ្រោះ។

របាយការណ៍ថ្មីបានបង្ហាញពីការប្រើប្រាស់កម្លាំងប្រដាប់អាវុធហួសហេតុ និងអំពើហឹង្សាកើនឡើង ដើម្បី បំបិទមាត់សកម្មជននិង សារព័ត៌មាន ក៏ដូចជាការបំបិទសិទ្ធិប្រជាពលរដ្ឋ ក្នុងការបញ្ចេញមតិក៏ដូចជាគម្រាមកំហែងលើអាយុជីវិតរបស់ពួកគេនៅក្នុងករណីមួយចំនួន។ ការជួបជុំគ្នានេះគឺជាឱកាសមួយដើម្បីធ្វើការតវ៉ា នូវវប្បធម៌ និទណ្ឌភាព និងសុំឲ្យបញ្ចប់និទណ្ឌភាពនៅកម្ពុជា។ វាក៏ជាទិវាមួយសម្រាប់ចងចាំ និងគោរព អ្នកកាសែតទាំងអស់ដែលត្រូវបានសំលាប់ ព្រោះក្នុងគោលបំណងនិងបេសកកម្មរបស់អ្នកសារព័ត៌មាន យើងខ្ញុំជឿជាក់ថាទិវានេះនឹងលើកកម្ពស់ការយល់ដឹងអំពីការបរាជ័យរបស់ រដ្ឋាភិបាលក្នុងការស្វែងរកឃាតករដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងសន្យាធ្វើសកម្មភាពបន្ថែមទៀត ដើម្បីស្វែងរក វិធីនៃការធ្វើឱ្យ អ្នកសារព័ត៌មាន មានសុវត្ថិភាព។

- **កញ្ញា សន វ៉ាម៉ាណា** អ្នកសម្របសម្រួលកម្រោងសេរីភាពនៃការបញ្ចេញមតិ ប្រចាំមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានមានប្រសាសន៍ថា៖ "បញ្ហានិទណ្ឌភាពនៅកម្ពុជាបច្ចុប្បន្ន គឺ មន្ត្រីអាក្រក់នៅតែមានសេរីភាពដើរហើរ ខណៈដែលសកម្មជនសិទ្ធិមនុស្សពុំមានកំហុស និងអ្នកសារព័ត៌មាន ត្រូវបានគេយាយី គំរាមកំហែង និងសម្លាប់ចំពោះការនិយាយរបស់ពួកគេ។ ករណីនៃការ រំលោភ បំពានទៅលើសកម្មជន និងអ្នកកាសែតទាំងនេះត្រូវបានអាជ្ញាធរមិនអើពើ និងធ្វើការដោះស្រាយ នោះឡើយ"។

- **លោក ប៉ា ងួនទៀង** នាយកប្រតិបត្តិ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមាន ប្រសាសន៍ថា៖ "ភាគច្រើននៃករណីទាំងនេះ គ្មានជនល្មើសណាគួរត្រូវបានចាប់ខ្លួនដើម្បីផ្តន្ទាទោសនោះទេ។ មានការយកចិត្តទុកដាក់តិចតួចណាស់ពីអាជ្ញាធរ ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះហើយក្រុមគ្រួសារនៅតែទន្ទឹងរង់ចាំយុត្តិធម៌។ វប្បធម៌និទណ្ឌភាពកើតឡើងជាស្ថានភាពនិទណ្ឌភាពចំពោះអ្នកទាំងឡាយណាដែលមានបំណងចង់ប្រើប្រាស់ហឹង្សា ដើម្បីបំបិទសំលេងរិះគន់ តែប៉ុណ្ណោះ។ នេះគឺជាការបំផ្លិចបំផ្លាញយ៉ាងខ្លាំងក្លាចំពោះប្រជាជនកម្ពុជា និងសិទ្ធិរបស់ពួកគេដែលត្រូវបានទទួល។ វាក៏ផ្តល់នូវការកើនឡើងនូវការបំបិទសិទ្ធិបុគ្គល នៅក្នុងចំណោមអ្នកសារព័ត៌មាន និងការគៀបសង្កត់លើសេរីភាពបញ្ចេញមតិ ហើយបទឧក្រិដ្ឋនៃការប្រឆាំងអ្នកសារព័ត៌មាន និងការយាយី ក៏គួរតែត្រូវបានបញ្ចប់"។

- **លោក យ៉េង វីរៈ** នាយកប្រតិបត្តិ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ មានប្រសាសន៍ថា៖ "បច្ចុប្បន្ន ប្រទេសកម្ពុជាបានបរាជ័យក្នុងការបញ្ចប់ទំព័រប្រវត្តិសាស្ត្ររបស់ខ្លួនអំពី របបខ្មែរក្រហមនិងរឿងអតីតកាល។ ហិង្សា និងនិទណ្ឌភាពនៅតែមាននៅក្នុងប្រទេសកម្ពុជា។ មេដឹកនាំបច្ចុប្បន្ននិងនា

ពេលអនាគតរបស់ប្រទេសនេះ គួរតែរៀនពីបទពិសោធន៍អតីតកាលរបស់ខ្លួន និងចៀសវាងពីការរំលោភសិទ្ធិមនុស្ស។ និទណ្ឌភាពត្រូវតែបញ្ឈប់ ដើម្បីជៀសវាងនូវ ប្រវត្តិសាស្ត្រច្រំដែល”។

វិទ្យុសម្លេងប្រជាធិបតេយ្យ នឹងរៀបចំកម្មវិធីពិសេសមួយ នៅវេលាម៉ោង ២ដល់ម៉ោង ៣រសៀល នៅថ្ងៃទី២១ វិច្ឆិកា នេះដើម្បីពិភាក្សាអំពីបញ្ហានិទណ្ឌភាព ដោយមានវាគ្មិនចូលរួមពីភរិយាលោក ហង្ស សេរីឧត្តម និងក្លឹបអ្នកកាសែតកម្ពុជា។ លោកអ្នកនាងអាចស្តាប់បានតាមរយៈ វិទ្យុសារិការ FM ១០៦.៥ រាជធានីភ្នំពេញ និង ៩៥.៥ ខេត្តសៀមរាប។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

**មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM)**
លោក ណុប វី (+៨៥៥ (0)៦០ ៨០៥ ៩៩៩/+ ៨៥៥ (0)១២ ៥១៩ ២៦១/ nopvy@vodhotnews.com)

**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)**
កញ្ញា សន រ៉ាមាណា (+៨៥៥ (0)១៧ ៦៥៥៥៩១/ ramana.sorn@cchrcambodia.org)

**មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍(CLEC)**
លោក ឌី ថេហូយ៉ា (+៨៥៥ (0)៦៦ ៧៧៧ ០១៥ /dythehoya@clec.org.kh)

**សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)**
លោក អំ សំអាត (+៨៥៥ (0) ១២ ៣២៧ ៧៧០, mon1@licadho-cambodia.org)